# កុំភ្លេចខ្លួន

## បទពាក្យ៨

ស្រុកកើតសង្គ្រាមឈាមអ្នកចម្បាំង　　ប្រយុទ្ធតតាំងដេញខ្មាំងឬស្សា
ឆក់ប្លន់ទឹកដីកេរគល់ខេមរា　　ដោយមហិច្ឆិតាទមិឡចិត្តទុយិស ។
ដៃកាន់អាវុធប្រយុទ្ធមិនរា　　យកទ្រូងការពារមិនគិតស្លាប់រស់
ថៃជាតិខេមរាសាសនាខ្ពង់ខ្ពស់　　អោយនៅមានឈ្មោះលើលោកនិរន្តរ៍ ។
ស្រុកចប់សង្គ្រាមព្យាយាមសិក្សា　　ស្វែងយល់កលការទមិឡចិត្តលោភលន់
ស្គាល់ល្បិចស្គាល់ស្នៀតស៊ីកសៀតដោយមន្ត　　មិនត្រូវបន្ទន់ភាន់ភាំងស្មារតី ។
ត្រូវគិតជានិច្ចល្បិចជនកំហូច　　គំនិតខិលខូចមិនចោលអតីត៍
ក្លែងធ្វើជាមិត្តគិតលួចទឹកដី　　ខ្មែរទាំងប្រុសស្រីមិនត្រូវភ្លេចខ្លួន ។
ស្រុកសន្តិភាពរាស្ត្ររៀបរាងរាយ　　កុំអាលរាយមាយធ្វើហំសមសួន
សប្បាយតែមុខទ្រូងទុក្ខផ្ទួនៗ　　សប្បាយភ្លេចខ្លួនស្ងួននឹងស្តាយក្រោយ ។
បើបានសប្បាយកុំណាយភ្លេចជាតិ　　ក្រែងកម្មបៀនបៀតយកសោកអោយសោយ
សត្រូវនៅមុខគេអាចបណ្តោយ　　សត្រូវនៅក្រោយត្រូវប្រុងប្រយ័ត្ន ។
បានផុតទុរ្ភិក្សត្រូវនឹកគុណភ្លៀង　　កុំដើរកាច់រាងធ្វើឫកអុងអាត់
សាច់ញាតិសន្ដានកុំចោលកុំកាត់　　ក្រែងមានវិបត្តិនឹករកគេជួយ ។
កើតមកជាមនុស្សត្រូវលុះសួស្តី　　រស់ដោយសេរីយកគុណធមិស្ងួយ
គ្មានសេរីភាពនឹងរងទុក្ខព្រួយ　　ជីវិតម្នាក់មួយកុំអោយគេជាន់ ។
ជំហរខ្លួនឯងជំទែងអោយរឹង　　ទប់ខ្លួនអោយនឹងប្រឹងអោយរួសរាន់
យកធមិនាំផ្លូវត្រាច់ទៅអោយទាន់　　គ្រប់កាលជំនាន់កុំភ្លេចអាត្មា ។
រស់លើលោកិយមានសេរីភាព　　ចេះអោនបន្ទាបកុំខ្លាចចេស្តា
ពួកពាលអប្រិយបិសាចហិង្សា　　គ្មានចិត្តមេត្តាកុំបីប្រហែស ។

Ca. ០៦ ឧសភា ២០០៦